**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ: សហព្រះរាជអាជ្ញា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១៧

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 08-Jun-2017, 13:55
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ : **សាធារណៈ/Public**

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ការកែតម្រូវរបស់សហព្រះរាជអាជ្ញានៅលើបញ្ជីអ្នកទោសមន្ទីរ ស-២១ របស់ ក.ស.ច.ស ដែលត្រូវបានពិនិត្យឡើងវិញ រួមជាមួយនឹងឧបសម្ព័ន្ធ ក, ខ និង គ**

---

<u>ដាក់ដោយ</u>៖

**សហព្រះរាជអាជ្ញា÷**
Nicholas KOUMJIAN
ជា លាង

<u>ផ្ញើជូន</u>៖

**អង្គជំនុំជម្រះសាលាដំបូង÷**
ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម **យ៉ា សុខន**
ចៅក្រម Claudia FENZ
ចៅក្រម **យូរ ឧត្តរា**

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី÷**
ពេជ អង្គ
Marie GUIRAUD

<u>ចម្លងជូន</u>៖

**ជនជាប់ចោទ÷**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្ដី÷**
សុន អរុណ
Victor KOPPEគង់ សំអុន
Anta GUISSÉ

## សារណា

1. នៅថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៧ សហព្រះរាជអាជ្ញាបានដាក់សេចក្តីសន្និដ្ឋានបញ្ចប់សវនាការដេញដោលរបស់ខ្លួន រួមជាមួយនឹងសំណៅដែលបានពិនិត្យឡើងវិញនៃបញ្ជីអ្នកទោសមន្ទីរ ស-២១ របស់ ក.ស.ច.ស ("បញ្ជីអ្នកទោសមន្ទីរ ស-២១ របស់ ក.ស.ច.ស ដែលត្រូវបានពិនិត្យឡើងវិញ"[1]។ តាមរយៈការពិនិត្យឡើងវិញរបស់ខ្លួនទៅលើឯកសារ ស-២១ នាសម័យកាលនោះដែលបានបកប្រែ និងមិនទាន់បានបកប្រែ ដែលរួមមាន បញ្ជីឈ្មោះអ្នកទោស និងបញ្ជីឈ្មោះដែលត្រូវសម្លាប់ ប្រវត្តិរូប ចម្លើយសារភាព និងរូបថត មានការបញ្ចូលឈ្មោះចំនួន ១៨.១៣៣ នាក់ នៅក្នុងបញ្ជីអ្នកទោសមន្ទីរ ស-២១ របស់ ក.ស.ច.ស ដែលត្រូវបានពិនិត្យឡើងវិញ[2]។

2. ចាប់តាំងពីបានដាក់បញ្ជីអ្នកទោសមន្ទីរ ស-២១ របស់ ក.ស.ច.ស ដែលត្រូវបានពិនិត្យឡើងវិញរួចមក សហព្រះរាជអាជ្ញាបានធ្វើការពិនិត្យឡើងវិញជាចុងក្រោយទៅលើការបញ្ចូលឈ្មោះ ដើម្បីដកចេញនូវសំណៅជាន់គ្នាដែលនៅសេសសល់ និងដើម្បីធានាឲ្យមានបញ្ជីឈ្មោះត្រឹមត្រូវនៃបុគ្គលដែលបានចូល និងបានស្លាប់នៅទួលស្លែង នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង មុនការពិភាក្សាសម្រេចរបស់អង្គជំនុំជម្រះ។

3. ការពិនិត្យឡើងវិញនេះបានបង្ហាញឲ្យឃើញថា មានការបញ្ចូលឈ្មោះចំនួន ៧០ ដែលសហព្រះរាជអាជ្ញាយល់ឃើញថា ទំនងជាការបញ្ចូលឈ្មោះបុគ្គលតែមួយជាន់គ្នា។ ក្នុងចំណោមការបញ្ចូលឈ្មោះជាន់គ្នាទាំងនេះ ឈ្មោះចំនួន ១០ មានប្រភពពីបញ្ជីឈ្មោះដំបូងរបស់ ក.ស.ច.ស និងឈ្មោះចំនួន ៦០ មានប្រភពពីបញ្ជីឈ្មោះបន្ថែមទៅនឹងបញ្ជីឈ្មោះដែលបានពិនិត្យឡើងវិញ ដែលបានធ្វើឡើងដោយសហព្រះរាជអាជ្ញា។ សហព្រះរាជអាជ្ញាយល់ឃើញថា ក.ស.ច.ស បានចំណាយពេលវេលា និងធនធានយ៉ាងច្រើនក្នុងការរៀបចំបញ្ជីឈ្មោះរបស់ខ្លួន និងបានពិនិត្យកំណត់ហេតុយ៉ាងហ្មត់ចត់

---

[1] ឯកសារ **E457/6/1** សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់សហព្រះរាជអាជ្ញា ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៧។

[2] ឯកសារ **E457/6/1.2.15/1** ឧបសម្ព័ន្ធ F.2 បញ្ជីអ្នកទោសមន្ទីរ ស-២១ របស់ ក.ស.ច.ស ដែលត្រូវបានពិនិត្យឡើងវិញ។

មុនពេលធ្វើការសន្និដ្ឋានថាការបញ្ចូលឈ្មោះទាំងអស់នៅក្នុងបញ្ជីឈ្មោះនោះគឺជាឈ្មោះបុគ្គលផ្សេងពីគ្នា។ ទោះបីយ៉ាងណាក៏ដោយ បន្ទាប់ពីបានពិនិត្យឡើងវិញ និងធ្វើការប្រៀបធៀបបន្ថែមទៀតរួចមក សហព្រះរាជអាជ្ញាយល់ឃើញថា ការបញ្ចូលឈ្មោះចំនួន ១០ ដែលបានរកឃើញនោះ តាមពិតគឺជាឈ្មោះជាន់គ្នា។ ក្នុងចំណោមការបញ្ចូលឈ្មោះចំនួន ៦០ ដែលបានរកឃើញនៅក្នុងបញ្ជីឈ្មោះបន្ថែមរបស់សហព្រះរាជអាជ្ញាថាជាឈ្មោះជាន់គ្នានោះ គឺភាគច្រើនមានប្រភពពីរូបថតអ្នកទោស ស-២១ ដែលនៅពេលនេះសហព្រះរាជអាជ្ញា បន្ទាប់ពីបានពិនិត្យឡើងវិញបន្ថែមទៀតដោយមានការប្រុងប្រយ័ត្នខ្ពស់នោះ ជឿជាក់ថា ទាក់ទិនទៅនឹងបុគ្គលដែលត្រូវបានដាក់បញ្ចូលក្នុងបញ្ជីឈ្មោះរួចហើយ តាមរយៈការលេចចេញនៅក្នុងកំណត់ហេតុនាសម័យកាលនោះក្នុងទម្រង់ផ្សេងទៀត[3]។ ដូច្នេះ ចំនួនសរុបនៃបុគ្គលដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងកំណត់ហេតុនាសម័យកាលនោះ ត្រូវបានកែតម្រូវពីចំនួន ១៨.១៣៣ នាក់ ទៅចំនួន ១៨.០៦៣ វិញ[4]។

4. ក្រៅពីបញ្ជីអ្នកទោសមន្ទីរ ស-២១ របស់ ក.ស.ច.ស ដែលត្រូវបានពិនិត្យឡើងវិញ សហព្រះរាជអាជ្ញាបានដាក់ (i) កម្រងតួលេខ និងតារាងចំនួន ៦០ (ឧបសម្ព័ន្ធ F2) និង (ii) ឧបសម្ព័ន្ធចំនួន ៥៧ (ឧបសម្ព័ន្ធ F3 ដល់ F57) ដែលបង្ហាញនូវព័ត៌មានលម្អិតនានាអំពីចំនួន និងប្រភេទអ្នកទោសនៅ ស-២១ នៅក្នុងពេលផ្សេងគ្នាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ចំនួនតិចតួចនៃតួលេខ តារាង និងឧបសម្ព័ន្ធទាំងនេះ រួមមានការបញ្ចូលឈ្មោះពីក្នុងចំណោមឈ្មោះជាន់គ្នាទាំង ៧០ នោះ[5]។ ក្នុងករណីដែលបញ្ហានេះបានកើតឡើងនោះ ផលប៉ះពាល់ទៅលើការវិភាគ គឺខុសគ្នាតិចជាង ១%[6]។ ដូច្នេះ សហព្រះរាជអាជ្ញា យល់ឃើញថា មិនចាំបាច់ត្រូវដាក់សំណៅពិនិត្យឡើងវិញទៅលើឧបសម្ព័ន្ធទាំងនេះឡើយ ដោយសារតែការវិភាគនៅក្នុងនោះមានភាពខុសគ្នាតិចតួចពេក។ ទោះបីយ៉ាងណាក៏ដោយ

---

[3] ក្នុងករណីដែលព័ត៌មាននៅក្នុងការបញ្ចូលឈ្មោះដែលត្រូវបានរកឃើញនៅពេលនេះថាជាការបញ្ចូលឈ្មោះជាន់គ្នា មិនមាននៅក្នុងការបញ្ចូលឈ្មោះដំបូងនៅក្នុងបញ្ជី ព័ត៌មាននោះត្រូវបានដាក់បញ្ចូលទៅក្នុងការបញ្ចូលឈ្មោះដំបូងនៅក្នុងឧបសម្ព័ន្ធ ក ដើម្បីផ្តល់នូវសេចក្តីលម្អិតឲ្យបានច្រើនតាមដែលអាចធ្វើបានសម្រាប់បុគ្គលនីមួយនៅក្នុងបញ្ជី។

[4] ឧបសម្ព័ន្ធ ក ភ្ជាប់មកជាមួយនឹងសំណើនេះ។

[5] ឧបសម្ព័ន្ធ ខ ភ្ជាប់មកជាមួយនឹងសំណើនេះ។

[6] ឧបសម្ព័ន្ធ ខ ភ្ជាប់មកជាមួយនឹងសំណើនេះ។

តារាងដែលភ្ជាប់មកជាមួយនេះ បង្ហាញអំពីសំណៅជាន់គ្នានីមួយៗនៃឧបសម្ព័ន្ធដែលរាប់ចំនួនពីរដង នូវអ្វីដែលយើងជឿជាក់នៅពេលនេះថាជាបុគ្គលតែមួយនោះ និងភាពផ្សេងគ្នាដែលការណ៍នេះ បានធ្វើឡើងចំពោះការវិភាគក្នុងឧសម្ព័ន្ធទាំងអស់នោះ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៧ | **លោកស្រី ជា លាង**<br>**សហព្រះរាជអាជ្ញាជាតិ** | ភ្នំពេញ | [signature] |
| | **លោក Nicholas KOUMJIAN**<br>**សហព្រះរាជអាជ្ញាអន្តរជាតិ** | | [signature] |